00159513

D427/1/A121/I

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

# ការិយាល័យសហចៅក្រមស៊ើបអង្កេត

ផ្ញើជូន: លោក អាង ឧត្តម និងលោក Michael G. Karnavas កាលបរិច្ឆេទ:២៤-០១-២០០៨

សហមេធាវីរបស់ អៀង សារី

តាមរយៈ

ពី: **ចៅក្រម យូ ប៊ុនឡេង**

**ចៅក្រម Marcel Lemonde**

សហចៅក្រមស៊ើបអង្កេត

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 25 / 01 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

កម្មវត្ថុ: សំណើសុំផ្តល់ព័ត៌មានទាក់ទិននឹងករណីទំនាស់ផលប្រយោជន៍ជាយថាហេតុ

លោកមេធាវីជាទីរាប់អាន

យើង បានទទួលលិខិតរបស់លោក ចុះថ្ងៃទី ១០ ខែមករា ឆ្នាំ ២០០៨ រួចហើយ ដែលតាមរយៈលិខិតនេះ លោកមេធាវី បានសួរថា វាជាការពិតដែរឬទេដែលមានអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតមួយរូប (លោក Stephen Heder) ធ្លាប់បំរើការងារនៅការិយាល័យសហព្រះរាជអាជ្ញាកាលពីមុនហើយ តើស្ថានភាពបែបនេះ អាចចោទជាបញ្ហានៃទំនាស់ផលប្រយោជន៍ ពិតប្រាកដមួយ ឬ ជាការប៉ាន់ស្មាន។

យើង សូមបញ្ជាក់ជូនលោកថា លោក Heder ត្រូវបានជ្រើសរើសឲ្យបំរើការងារសម្រាប់ UNAKRT (ជំនួយការនៃអង្គការសហប្រជាជាតិសម្រាប់ការកាត់ទោសខ្មែរក្រហម/Assistance des Nations Unies au procès des Khmers rouges) ដោយការិយាល័យសម្រាប់កិច្ចការសេដ្ឋកិច្ច និងសង្គមរបស់អង្គការសហប្រជាជាតិ នៅខែកក្កដា ឆ្នាំ ២០០៦ សម្រាប់បំរើការងារនៅការិយាល័យសហចៅក្រមស៊ើបអង្កេត។ ប៉ុន្តែ មុននឹងចូលមកបំរើការងារនៅការិយាល័យសហចៅក្រមស៊ើបអង្កេត គាត់ ត្រូវបានចាត់ឲ្យទៅធ្វើការនៅការិយាល័យសហព្រះរាជអាជ្ញា ចាប់ពីខែកក្កដា ដល់ខែធ្នូ ឆ្នាំ២០០៦។

ORIGINAL DOCUMENT
RECEIVED ON 25-01-2008
AT: 11:45
BY SANN RADA
COURT OFFICER



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុងភ្នំពេញ
ទូរស័ព្ទ: ០២៣ ២១៩៨១៤ ទូរសារ: ០២៣ ២១៩៨៤១ ប្រអប់សំបុត្រ ៧១ ក្រុងភ្នំពេញ កម្ពុជា

ស្ថានភាពបែបនេះ មិនមានអ្វីចម្លែកទេ។ ជាក់ស្តែង បើយោងតាមបទប្បញ្ញត្តិនៃវិធានផ្ទៃក្នុងដែលចែងពីករណីនេះ (វិធាន ១៣(៤) វិធាន ១៤(៥) វិធាន ១៦ វិធាន ៥០(២) វិធាន៥៥(៩) វិធាន ៦២) អ្នកស៊ើបអង្កេតនៃ អ.វ.ត.ក មានលក្ខណៈដូចគ្នានឹងមន្ត្រីនគរបាលយុត្តិធម៌ៈ ស្ថិតនៅក្រោមនីតិវិធីនៃការទទួលនីតិសម្បទាដូចគ្នា និងលើកលែងតែវិធានការណ៍បង្ខំចេញដែលជាសមត្ថកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌តែមួយគត់ អ្នកស៊ើបអង្កេតមានតួនាទីដូចគ្នានឹងមន្ត្រីនគរបាលយុត្តិធម៌ ក្នុងក្របខ័ណ្ឌនៃការស៊ើបអង្កេតបឋម និងការស៊ើបអង្កេត ដោយខ្លួនបំពេញតួនាទីនេះនៅក្រោមការគ្រប់គ្រងរបស់ចៅក្រមមានសមត្ថកិច្ច។

បទប្បញ្ញត្តិនៃវិធានផ្ទៃក្នុងនេះ ទទួលឥទ្ធិពលដោយផ្ទាល់ពីច្បាប់ប្រទេសកម្ពុជា ដែលកំណត់ថា នគរបាលយុត្តិធម៌ បំពេញការងារក្រោមអំណាចរបស់ព្រះរាជអាជ្ញា ក្នុងដំណាក់កាលស៊ើបអង្កេតបឋម ឬ ចៅក្រមស៊ើបអង្កេត នៅក្នុងដំណាក់កាលនៃការស៊ើបសួរ (យោងមាត្រា ៣៧ វាក្យខ័ណ្ឌ ១ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា)។

ការអនុវត្តន៏បែបនេះ ជារួម ត្រូវបានអនុញ្ញាតនៅគ្រប់ប្រទេសទាំងអស់ ដែលអនុវត្តប្រព័ន្ធនីតិវិធីដូចគ្នានឹងប្រទេសកម្ពុជា (សូមអានមាត្រា ១៤ មាត្រា ៧៥ និងមាត្រា ១៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌបារាំង មាត្រា ៩ និងមាត្រា ៥៦ នៃក្រមស៊ើបសួរបទព្រហ្មទណ្ឌប្រទេសបែលហ្ស៊ិក ។ល។) ដូចគ្នាដែរ យុត្តិសាស្ត្រ ក៏បានរំលឹកផងដែរថា វិធានដែលចែងអំពីវិសមិតភាពនៃមុខងារ ដែលមានគោលដៅធានាឯករាជ្យភាព និងអនាគតិតុលាការនោះ សំដៅតែទៅលើចៅក្រមប៉ុណ្ណោះ និង មិនអនុវត្តចំពោះអ្នកស៊ើបអង្កេតទេ។

ស្ថានភាពដែលលោកបានលើកឡើងនៅក្នុងលិខិតចុះថ្ងៃទី ១០ ខែមករា ឆ្នាំ ២០០៨ គឺមិនបង្កជាបញ្ហាណាមួយដល់ឯករាជ្យភាព និងអនាគតិរបស់សហចៅក្រមស៊ើបអង្កេតទេ ហើយ ក៏មិនមានអ្វីប៉ះពាល់ដល់ដំណើរការល្អនៃការស៊ើបអង្កេតដែលកំពុងតែដំណើរការនេះដែរ។

សូមលោកទទួលនូវការរាប់អានអំពីយើង។

E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុងភ្នំពេញ
ទូរស័ព្ទ: ០២៣ ២១៩៨១៤ ទូរសារ: ០២៣ ២១៩៨៤១ ប្រអប់សំបុត្រ ៧១ ក្រុងភ្នំពេញ កម្ពុជា